**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
KINGDOM OF CAMBODIA
*Nation - Religion - King*

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ០៤៨០ ព.ណ. ...

ភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឱ្យបានជ្រាបថា៖ ក្នុងយុទ្ធសាស្ត្រជួយជំរុញ និងលើកកម្ពស់ផលិតផលក្នុងស្រុកឱ្យមានការទទួលស្គាល់ និងចូលរួមប្រើប្រាស់កាន់តែទូលំទូលាយនៅទូទាំងប្រទេស ក្រសួងពាណិជ្ជកម្ម នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ "យុទ្ធនាការទិញផលិតផលខ្មែរ" ក្នុងឱកាសបុណ្យទន្លេឆ្នាំ២០១៧ នៅខេត្តស្ទឹងត្រែង ចាប់ពីថ្ងៃទី ២៤-២៦ ខែមីនា ឆ្នាំ២០១៧។

ការរៀបចំពិព័រណ៍នេះ ក្នុងគោលបំណងចង់ស្វះរពញ្ញាក់ស្មារតីមហាជនទូទៅ ឱ្យងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុកឱ្យបានច្រើនជាអតិបរិមា។ ក្រសួងពាណិជ្ជកម្ម នឹងប្រមូលរៀផលិតផលខ្មែរ មានគុណភាពខ្ពស់ មានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ មានការវេចខ្ចប់បានល្អត្រឹមត្រូវ អនុលោមតាមស្តង់ដារ ផលិតកម្មពីគ្រប់ទិសទីនៅទូទាំងប្រទេស មកដាក់តាំងបង្ហាញ និងស្វែងរកដៃគូយកទៅលក់បន្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញ លោក លោកស្រី ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផលខ្មែរក្នុងព្រឹត្តិការណ៍នេះ សូមប្រញាប់ប្រសាន់មកដាក់ពាក្យចូលរួម ព្រោះចំនួនស្តង់មានកំណត់។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសាធារណជនទូទៅចូលរួមទស្សនា និងគាំទ្រព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ កុំបីខកខានឡើយ។

ចំពោះព័ត៌មានលម្អិតផ្សេងៗ ស្តីពីការរៀបចំពិព័រណ៍ខាងលើ សូមទំនាក់ទំនងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមទូរស័ព្ទលេខ ០៧៨ ៧៣៧ ៧៨៧/ ០៧៧ ៣៣៩ ៨៣៩/ ០១២ ៩៤០ ៨២៩/ ០១២ ៥៥០ ៦៣៥/ ០១២ ៨៤២ ១១៩ ឬអ៊ីម៉ែល៖ nemoeang@gmail.com, eng.sokneary@yahoo.com, rithyco@yahoo.com, sokdarith72@gmail.com។

**សូមអរគុណ!**